# រឿងបុរស ៣ ឈ្លោះដណ្ដើមដំណេកគ្នា

# ប្រជុំរឿងព្រេងខ្មែរភាគ ៣ ទំព័រ ២១ - ២២

មាននិទានមួយថា : មានបុរស ៣ នាក់វិវាទជជែកប្រកែក ដណ្ដើមដំណេកគ្នា ចង់ដេកកណ្ដាលតែរៀងខ្លួន ។ បុរសទាំង ៣ នាក់នោះក្រវើនតែ១ ប្រកែកជជែកគ្នាទៅវិញទៅមក ក៏ខានបានដេកយប់នោះ ។ លុះព្រឹកឡើងក៏នាំគ្នាទៅរកចៅក្រមប្ដឹងដោយដំណើរទីទៃ ។ ។ ចៅក្រមពិចារណាក្ដីនេះពុំដាច់ស្រេច ក៏នាំបុរសទាំង ៣ នាក់ទៅក្រាបបង្គំទូលព្រះមហាក្សត្រ ដោយដំណើរនោះ ។ ព្រះអង្គទ្រង់ព្រះសណ្ដាប់ហើយ ទ្រង់ព្រះតម្រិះដោយព្រះប្រាជ្ញា ឈ្វេងយល់ក្នុងព្រះវិចារណញ្ញាណ ហើយទ្រង់ត្រាស់បង្គាប់ថា "ចូរព្រះស្ដែងទាំង ៣ នាក់ដេកយកក្បាលឈមជុំចូលរកគ្នា នេះឯងហៅថាដេកកណ្ដាលគ្រប់គ្នាហោង " ។

បុរសទាំង ៣ នាក់ទទួលព្រះបន្ទូលនោះហើយ ក៏ក្រាបថ្វាយបង្គំលាព្រះមហាក្សត្រទៅលំនៅរៀងខ្លួន ។

ព្រះមហាក្សត្រទ្រង់កាត់សេចក្ដីដូច្នេះ ហៅសុគតិគមនំហោង ។